# អបអរសាទរទិវាគ្រូបង្រៀនពិភពលោក
# សុន្ទរកថាស្វាគមន៍របស់ លោក សាដា អ៊ូម៉ា អាឡាម
# តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា

ប្រធានបទជាតិ៖ ការអភិវឌ្ឍគ្រូបង្រៀន ដើម្បីអភិវឌ្ឍមូលធនមនុស្សឆ្ពោះទៅកាន់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០

ប្រធានបទសាកល៖ ការផ្តល់តម្លៃលើសម្លេងគ្រូបង្រៀន៖ ឆ្ពោះទៅរកការផ្តល់កិច្ចសន្យាការងារល្អប្រសើរនៅក្នុងវិស័យអប់រំ

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០២៤

**សូមគោរព៖**

- ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធ
- លោកគ្រូ អ្នកគ្រូ នាយក នាយិកា គ្រូឧទ្ទេស តំណាងដៃគូអភិវឌ្ឍន៍ លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីគោរពរាប់អាន!

**ខ្លឹមសារគន្លឹះ**

- ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោកគ្រូ អ្នកគ្រូ លោក លោកស្រី អ្នកនាងកញ្ញានៅថ្ងៃនេះ ដើម្បីអបអរសាទរការរួមចំណែកនិងការលះបង់ដែលមិនអាចកាត់ថ្លៃបានរបស់គ្រូបង្រៀននៅទូទាំងប្រទេសកម្ពុជា នាឱកាសដ៏ពិសេសនេះនៃទិវាគ្រូបង្រៀនពិភពលោក។ តាងនាមអង្គការយូណេស្កូ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះឡើង និងការប្តេជ្ញាចិត្តដ៏មោះមុតក្នុងការអភិវឌ្ឍនិងការផ្តល់ភាពអង់អាចដល់គ្រូបង្រៀននៅកម្ពុជា។

- នាថ្ងៃនេះ ខណៈពេលដែលយើងជួបជុំគ្នានៅទីនេះ ក្រោមប្រធានបទជាតិ «ការអភិវឌ្ឍគ្រូបង្រៀន ដើម្បីអភិវឌ្ឍមូលធនមនុស្សឆ្ពោះទៅកាន់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០» យើងបានរំឭកអំពីតួនាទីដ៏សំខាន់របស់គ្រូបង្រៀនសម្រាប់ការតម្រង់ទិសផ្នត់គំនិតដល់សិស្សានុសិស្ស និងការកសាងអនាគតដ៏រុងរឿងសម្រាប់ប្រទេសកម្ពុជា។

- ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ កំណែទម្រង់អប់រំគ្រូបង្រៀននៅប្រទេសកម្ពុជាមានការរីកចម្រើនជាលំដាប់។ អង្គការយូណេស្កូសូមអបអរសាទរក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការបោះពុម្ពផ្សាយរបាយការណ៍ដ៏លេចធ្លោមួយ ដែលបង្ហាញពីសមិទ្ធផលស្តែងចេញពីកំណែទម្រង់នេះចាប់តាំងពីឆ្នាំ២០១៤មក រួមមានការកែលម្អគ្រឹះស្ថានអប់រំគ្រូបង្រៀន ការលើកកម្ពស់គុណវុឌ្ឍិនិងស្តង់ដាគ្រូបង្រៀន និងការវិនិយោគលើការអភិវឌ្ឍគ្រូបង្រៀន។ អង្គការយូណេស្កូសូមកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា សម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការជ្រើសរើសគ្រូបង្រៀនប្រកបដោយជោគជ័យនាពេលថ្មីៗនេះ។ សមិទ្ធផលទាំងអស់នេះ គឺជាលក្ខខណ្ឌសំខាន់សម្រាប់ទាក់ទាញបេក្ខជនដែលមានគុណភាពឱ្យចាប់យកអាជីពជាគ្រូបង្រៀន និងកសាងសមត្ថភាពគ្រូបង្រៀនដ៏រឹងមាំ។

- អង្គការយូណេស្កូបានធ្វើការជាដៃគូដ៏យូរអង្វែងជាមួយក្រសួងអប់រំ យុវជន និងកីឡានៅក្នុងដំណើរការបរិវត្តកម្មនេះ។ ចាប់ពីឆ្នាំ២០១៨មក ក្រសួងអប់រំនិងអង្គការយូណេស្កូបានដាក់ឱ្យដំណើរការកម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា ហៅកាត់ថា STEPCam ដែលមានទឹកប្រាក់ចំនួន២៧.០២ លានដុល្លារ និងគាំទ្រថវិកាដោយភាពជាដៃគូសកលសម្រាប់ការអប់រំ។ គ្រូបង្រៀនតែងតែស្ថិតនៅចំណុចកណ្តាលនៃចក្ខុវិស័យរួមរបស់យើង។ យើងទទួលស្គាល់ថាគ្រូបង្រៀនគឺជាបេះដូងនៃការអប់រំ ដែលជាមធ្យោបាយដ៏មានឥទ្ធិពលបំផុតសម្រាប់ការលើកកម្ពស់ធនធានមនុស្ស ការសម្រេចបាននូវវឌ្ឍនភាពសង្គម និងបរិវត្តកម្មសង្គមរបស់យើង។ កម្មវិធី STEPCam គឺជាកម្មវិធីមួយមានវិសាលភាពដ៏ធំនិងស៊ីជម្រៅ ក្នុងចំណោមកម្មវិធីអប់រំគ្រូបង្រៀនទាំងឡាយនៅកម្ពុជា និងបានផ្តល់អត្ថប្រយោជន៍ដល់សិស្សានុសិស្ស និងបុគ្គលិកអប់រំរាប់សែននាក់នៅទូទាំងប្រទេសកម្ពុជាចាប់តាំងពីបានដាក់ឱ្យដំណើរការកម្មវិធីនេះមក។

- ក្នុងដំណើរការឆ្ពោះទៅរកចក្ខុវិស័យរបស់ប្រទេសកម្ពុជាឆ្នាំ២០៥០ គ្រូបង្រៀននឹងបន្តដើរតួជាភ្នាក់ងារនៃការផ្លាស់ប្តូរ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទីមួយ ហើយទទួលស្គាល់ថាបរិវត្តកម្មអប់រំចាប់ផ្តើមពីគ្រូបង្រៀន។ ស្របពេលដែលប្រទេសកម្ពុជាកំពុងរៀបចំខ្លួនក្នុងការចាកចេញពីចំណាត់ក្រុមប្រទេសមានការអភិវឌ្ឍតិចតួច (LDC) គ្រូបង្រៀននៅតែជាចំណុចស្នូលនៃចក្ខុវិស័យនេះ ហើយត្រូវតែទទួលបានការអភិវឌ្ឍវិជ្ជាជីវៈ ការទទួលស្គាល់ និងការគាំទ្រពេញលេញ ដើម្បីបំផុសគំនិតនិងត្រួសត្រាយផ្លូវដល់អ្នកជំនាន់ក្រោយ។

- ទិវាគ្រូបង្រៀនពិភពលោកឆ្នាំ២០២៤ បានប្រារព្ធឡើងក្រោមប្រធានបទអន្តរជាតិ «ការផ្តល់តម្លៃលើសម្លេងគ្រូបង្រៀន៖ ឆ្ពោះទៅរកការផ្តល់កិច្ចសន្យាការងារល្អប្រសើរនៅក្នុងវិស័យអប់រំ»។ ប្រធានបទនេះបង្ហាញពីសារៈសំខាន់នៃការផ្តល់តម្លៃលើទស្សនៈរបស់គ្រូបង្រៀនជាកតាលីករសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន និងការបង្កើតបរិយាកាសគាំទ្រសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេ។

- ក្នុងឱកាសប្រារព្ធទិវាគ្រូបង្រៀននាថ្ងៃនេះ យើងរួមគ្នារំឭកដល់គុណូបការៈនិងឥទ្ធិពលដ៏ធំធេងរបស់គ្រូបង្រៀនមកលើយើងទាំងអស់គ្នា។ យើងរួមគ្នាធានាឱ្យបានថាគ្រូបង្រៀនគ្រប់រូបទទួលបានការគាំទ្រគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវសក្តានុពលពេញលេញសម្រាប់ការដឹកនាំនិងត្រួសត្រាយផ្លូវដល់យុវជនកម្ពុជាជំនាន់ក្រោយ។ តាមរយៈការផ្តល់ឱកាសអភិវឌ្ឍវិជ្ជាជីវៈ ឧបករណ៍និងវិធីសាស្ត្របង្រៀនប្រកបដោយនវានុវត្តន៍ សមត្ថភាពឌីជីថល និងការលើកកម្ពស់ឋានៈវិជ្ជាជីវៈដល់គ្រូបង្រៀន យើងនឹងអាចធានាបានថាកុមារកម្ពុជាគ្រប់រូបនឹងរីកលូតលាស់ និងមានបំណិនមូលដ្ឋានគ្រឹះរឹងមាំក្នុងការសម្រេចបាននូវជោគជ័យនាពេលអនាគត។

- នាពេលខាងមុខនេះ អង្គការយូណេស្កូ រួមជាមួយនឹងដៃគូអភិវឌ្ឍន៍នានា នឹងបន្តគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន តាមរយៈការតាក់តែងគោលនយោបាយ និងការស្រាវជ្រាវស្តីពីការអប់រំគ្រូបង្រៀន ការគ្រប់គ្រង និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ អង្គការយូណេស្កូនឹងបន្តគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំច្រកបណ្តុះបណ្តាលសម្រាប់ចាប់យកអាជីពជាគ្រូបង្រៀនបឋមសិក្សា។ យើងនឹងពង្រឹង និងពង្រីកប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីផ្តល់ឱកាសដល់គ្រូបង្រៀនគ្រប់រូបក្នុងការពង្រឹងសមត្ថភាព និងដំឡើងគុណវុឌ្ឍិ។ យើងនឹងបន្តវិនិយោគលើកម្មវិធីសិក្សាកម្រិតថ្នាក់ដំបូង ដើម្បីធានាថាសិស្សានុសិស្សនៅកម្រិតថ្នាក់ដំបូងទទួលបានការអភិវឌ្ឍសមត្ថភាពមូលដ្ឋានគ្រឹះដ៏រឹងមាំ។ នៅក្នុងពិភពលោកដែលមានការផ្លាស់ប្តូរដ៏ឆាប់រហ័សជំរុញដោយបច្ចេកវិទ្យា យើងនឹងបន្តគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការវិនិយោគលើបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងបរិវត្តកម្មឌីជីថលក្នុងវិស័យអប់រំ ជួយគ្រូបង្រៀនឱ្យចេះប្រើប្រាស់ឧបករណ៍និងបច្ចេកវិទ្យាឌីជីថល សម្រាប់គាំទ្រការសិក្សារបស់សិស្សានុសិស្សទាំងនៅក្នុងនិងក្រៅថ្នាក់រៀន។

- អង្គការយូណេស្កូនឹងបន្តឈរជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងបេសកកម្មដ៏សំខាន់នេះដើម្បីគាំទ្រគ្រូបង្រៀនក្នុងការបំពេញតួនាទីស្នូលជាកម្លាំងចលករជម្រុញការអភិវឌ្ឍជាតិនៅកម្ពុជា។ យើងទន្ទឹងរង់ចាំនិងបានត្រៀមខ្លួនរួចរាល់ដើម្បីបន្តភាពជាដៃគូដ៏រឹងមាំនេះនាពេលខាងមុខ។

- ជូនចំពោះលោកគ្រូអ្នកគ្រូទាំងអស់ដែលមានវត្តមានក្នុងពិធីនេះ និងនៅទូទាំងប្រទេសកម្ពុជា យើងខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការចំពោះការលះបង់និងការរួមចំណែករបស់លោកគ្រូអ្នកគ្រូ។ យើងបានឃើញច្បាស់ការងារដែលលោកគ្រូអ្នកគ្រូបានបំពេញ និងសូមអបអរសាទរលោកគ្រូអ្នកគ្រូ! អបអរសាទរទិវាគ្រូបង្រៀនពិភពលោក!